ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូងខេត្តកណ្តាល

សំណុំរឿងព្រហ្មទណ្ឌ
លេខ ១១០១ អក
ចុះថ្ងៃទី២៧ ខែមិថុនា ឆ្នាំ២០២៣
សាលក្រមព្រហ្មទណ្ឌ
លេខ ១១៤ "ង១"
ចុះថ្ងៃទី២៦ ខែធ្នូ ឆ្នាំ២០២៣

# តាងនាមប្រជារាស្ត្រខ្មែរ
# សាលាដំបូងខេត្តកណ្តាល

បានបើកសវនាការជាសាធារណៈនាថ្ងៃទី០៥ ខែតុលា ឆ្នាំ២០២៣ និងប្រកាសជាសាធារណៈនៅថ្ងៃទី២៦ ខែធ្នូ ឆ្នាំ២០២៣ ដែលមានសមាសភាពដូចខាងក្រោម៖

**សមាសភាពជំនុំជម្រះ**

លោក [redacted] ចៅក្រមជំនុំជម្រះ

**តំណាងអយ្យការ**

លោក [redacted] ព្រះរាជអាជ្ញារង

**ក្រឡាបញ្ជីសវនាការ**

លោកស្រី [redacted] ក្រឡាបញ្ជី ·

ដើម្បីជំនុំជម្រះលើសំណុំរឿងព្រហ្មទណ្ឌលេខ ១១០១ អ.ក ចុះថ្ងៃទី២៧ ខែមិថុនា ឆ្នាំ២០២៣ ដែលមានជនជាប់ចោទ៖

១. ឈ្មោះ [redacted]ម៉េងអ៊ី ភេទប្រុស អាយុ ២០ឆ្នាំ ជនជាតិខ្មែរ សញ្ជាតិខ្មែរ មុខរបរបុគ្គលិកយូនីលីវើ មានទីកន្លែងកំណើត និងទីលំនៅបច្ចុប្បន្ននៅភូមិ[redacted] ខេត្តកណ្តាល ឪពុកឈ្មោះ លី (រស់) ម្តាយឈ្មោះ [redacted]សុខ (រស់) នៅលីវ ជានីតិជន ទោសពីមុនគ្មាន។(ក្នុងឃុំ)

២-ឈ្មោះ [redacted]រាជសី ភេទប្រុស អាយុ ២១ឆ្នាំ ជនជាតិខ្មែរ សញ្ជាតិខ្មែរ មុខរបរបើកឡានដឹកដី មានទីកន្លែងកំណើត និងមានទីលំនៅបច្ចុប្បន្ននៅភូមិ[redacted] ខេត្តព្រះវិហារ ឪពុកឈ្មោះ [redacted]សូ (រស់) ម្តាយឈ្មោះ [redacted] ផល្លី (រស់) នៅលីវ ជានីតិជន ទោសពីមុនគ្មាន។ (ក្នុងឃុំ)

៣-ឈ្មោះ [redacted] ចាន់ណា ភេទប្រុស អាយុ ២៤ឆ្នាំ ជនជាតិខ្មែរ សញ្ជាតិខ្មែរ មុខរបរកសិករ មានទីកន្លែងកំណើត និងទីលំនៅបច្ចុប្បន្ននៅភូ[redacted] ខេត្តកណ្តាល ឪពុកឈ្មោះ [redacted]ឆេងអាន (រស់) ម្តាយឈ្មោះ [redacted] ស្រីមៅ (រស់) នៅលីវ ជានីតិជន។ (គេចខ្លួន)

ជាប់ចោទពីបទ៖ ហិង្សាដោយចេតនាមានស្ថានទម្ងន់ទោស និងធ្វើឱ្យខូចខាតដោយចេតនាមានស្ថានទម្ងន់ទោស ប្រព្រឹត្តនៅភូមិព្រែកតាបែន ឃុំស្វាយរមៀត ស្រុកខ្សាច់កណ្តាល ខេត្តកណ្តាល កាលពីថ្ងៃទី២៥ ខែមិថុនា ឆ្នាំ២០២៣ តាមបញ្ញត្តិមាត្រា ២១៨ និងមាត្រា ៤១១ នៃក្រមព្រហ្មទណ្ឌ។

ដែលមានលោក [redacted] ជា



Scanned with CamScanner

មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទឈ្មោះ [redacted] ម៉េងអ៊ី។

**ការប្រព្រឹត្តរបស់ជនជាប់ចោទខាងលើមានដូចតទៅ៖**

កាលពីថ្ងៃទី២៥ ខែមិថុនា ឆ្នាំ២០២៣ វេលាម៉ោង ២២ និង ០០នាទី ជនត្រូវចោទឈ្មោះ [redacted] ម៉េងអ៊ី ភេទប្រុស អាយុ ២០ឆ្នាំ និងឈ្មោះ [redacted] ចាន់ណា (ហៅបារ) ភេទប្រុស អាយុ ២០ឆ្នាំ បានជិះម៉ូតូមួយគ្រឿងម៉ាក IVINER.X ពណ៌បៃតង ចូលទៅក្នុងវត្តស្វាយរមៀត ស្ថិតនៅក្នុងភូមិព្រែកតាបែន ឃុំស្វាយរមៀត ស្រុកខ្សាច់កណ្តាល ខេត្តកណ្តាល ធ្វើសកម្មភាពកាប់បំផ្លាញម៉ូតូរបស់ឈ្មោះ [redacted] រ៉ាឈី ភេទប្រុស អាយុ ៣០ឆ្នាំ រួចហើយនាំគ្នាជិះម៉ូតូគេចខ្លួនទៅឃ្លោងទ្វារវត្តស្វាយរមៀតក៏បានដួលម៉ូតូ ភ្លាមៗនោះឈ្មោះ [redacted] រ៉ាឈី និងឈ្មោះ [redacted] មុន្នី នាំគ្នាជិះម៉ូតូដេញតាមទាន់ ហើយឈ្មោះ [redacted] មុន្នី បានចុះពីលើម៉ូតូរត់តាមឈ្មោះ [redacted] ម៉េងអ៊ី ក៏ត្រូវឈ្មោះ [redacted] ម៉េងអ៊ី រើសដំបងឬស្សីវាយក្បាលរបស់ឈ្មោះ [redacted] មុន្នី ចំនួន ០៣ដំបងផ្ទួនៗគ្នា បណ្តាលឱ្យរបួសបែកក្បាលហូរឈាម ហើយឈ្មោះ [redacted] ម៉េងអ៊ី បានរត់ទៅរកបក្ខពួករបស់ខ្លួន មានឈ្មោះ [redacted] ចាន់ណា (ហៅបារ) ប្រដាប់ដោយដាវ និងឈ្មោះ [redacted] រាជសី ប្រដាប់ដោយកាំបិតខ្មែរ រួចនាំគ្នាស្ទុះចូលទៅកាប់ឈ្មោះ [redacted] មុន្នី និងឈ្មោះ [redacted] រ៉ាឈី ឃើញដូច្នេះឈ្មោះ [redacted] មុន្នី និងឈ្មោះ [redacted] រ៉ាឈី បានផ្តួលម៉ូតូរត់យករួចខ្លួនទៅ ដោយដេញកាប់ជនរងគ្រោះមិនបានជនត្រូវចោទឈ្មោះ [redacted] ចាន់ណា និងឈ្មោះ [redacted] រាជសី បានកាប់បំផ្លាញម៉ូតូរបស់ឈ្មោះ [redacted] រ៉ាឈី ម៉ាកស្កុបពី ពណ៌ខ្មៅ ពាក់ផ្លាកលេខ ភ្នំពេញ 1KB-5516 បណ្តាលឱ្យបែកបាក់ខូចខាតម៉ូតូយ៉ាងដំណំ។ ភ្លាមៗនោះស្រាប់សមត្ថកិច្ចបានចុះទៅដល់កន្លែងកើតហេតុ ស្រាប់តែជនត្រូវចោទនាំគ្នារត់គេចពីកន្លែងកើតហេតុបន្សល់ទុកម៉ូតូចំនួន ០២គ្រឿងខាងលើនៅនឹងកន្លែងកើតហេតុ។ សមត្ថកិច្ចបានចាប់យកវត្ថុតាងមាន ម៉ូតូចំនួន ០២គ្រឿង ម៉ាក IVINER.X និងម៉ាក ស្កុបពី ខាងលើយកប៉ុស្តិ៍នគរបាលរដ្ឋបាលស្វាយរមៀត។ លុះដល់ថ្ងៃទី២៦ ខែឆ្នាំដដែល ជនត្រូវចោទឈ្មោះ [redacted] ម៉េងអ៊ី បានទៅប៉ុស្តិ៍នគរបាលបំណាងសួររកម៉ូតូក៏ត្រូវសមត្ថកិច្ចចាប់ខ្លួន និងបន្តទៅចាប់ខ្លួនជនត្រូវចោទម្នាក់ទៀតឈ្មោះ [redacted] រាជសី ព្រមទាំងចាប់យកវត្ថុតាង កាំបិតខ្មែរដងឬស្សីចំនួន ០១ដើម និងដាវដែកចំនួន ០១ដើមបន្ថែមទៀត រួចនាំខ្លួនជនត្រូវចោទយកទៅសាកសួរ និងកសាងសំណុំរឿងបញ្ជូនជនត្រូវចោទ ព្រមទាំងវត្ថុតាងរួមមាន ដាវចំនួន ០១ដើម និងកាំបិតខ្មែរចំនួន ០១ដើម មកអយ្យការអមសាលាដំបូងខេត្តកណ្តាល ដើម្បីចាត់ការតាមនីតិវិធីច្បាប់។

-បានឃើញ ដីកាបញ្ជូនរឿងឱ្យស៊ើបសួរលេខ ៨៥៧ ដកសស ចុះថ្ងៃទី២៧ ខែមិថុនា ឆ្នាំ២០២៣ របស់តំណាងអយ្យការសាលាដំបូងខេត្តកណ្តាល ។

-បានឃើញ ដីកាសន្និដ្ឋានស្ថាពរលេខ ១១៥១ ដកសព ចុះថ្ងៃទី០៧ ខែកញ្ញា ឆ្នាំ២០២៣ របស់ចៅក្រមស៊ើបសួរសាលាដំបូងខេត្តកណ្តាល ។

-បានឃើញ ដីកាដំណោះស្រាយលេខ ១១៧២ ដកដស ចុះថ្ងៃទី១២ ខែកញ្ញា ឆ្នាំ២០២៣ របស់ចៅក្រមស៊ើបសួរសាលាដំបូងខេត្តកណ្តាល ។

-បានឃើញ ដីកាចាត់តាំងចៅក្រមជំនុំជម្រះលេខ ១២៦០ ដកចត ចុះថ្ងៃទី២៧ ខែមិថុនា ឆ្នាំ២០២៣ របស់ប្រធានសាលាដំបូងខេត្តកណ្តាល ។

**នាពេលសវនាការ**

១- ជនជាប់ចោទឈ្មោះ [redacted] រាជសី បានឆ្លើយថា៖ កាលពីថ្ងៃទី២៥ ខែមិថុនា ឆ្នាំ២០២៣ ម៉ោង ៦ល្ងាច ខ្លួនកំពុងតែនៅកន្លែងស្នាក់នៅរបស់ខ្លួន ស្រាប់តែមានមិត្តភក្តិរបស់ខ្លួនឈ្មោះ អ៊ី ភេទប្រុស នៅភូមិស្វាយរមៀត ឃុំព្រែកតាមាក់ ស្រុកខ្សាច់កណ្តាល ខេត្តកណ្តាល ជិះម៉ូតូម៉ាកហុងដាសេ ១២៥ ពណ៌ខ្មៅ ស៊េរីឆ្នាំ ២០២២ ឌុបមនុស្សម្នាក់មិនស្គាល់ឈ្មោះ មកបបួលខ្លួនទៅផឹកស៊ីនៅផ្ទះរបស់ឈ្មោះ អ៊ី នៅឃុំស្វាយរមៀត



Scanned with CamScanner

ហើយឈ្មោះ អ៊ី ជិះម៉ូតូឌុបខ្លួន និងមនុស្សម្នាក់នោះទៅផ្ទះមួយនៅខាងត្បូងវត្តស្វាយរមៀត ចំងាយប្រហែល ៣០០ម៉ែត្រ ឈ្មោះ អ៊ី បានឌុបពួកខ្លួនចូលទៅបានជួបមនុស្សប្រុសដែលជាម្ចាស់ផ្ទះ និងប្រុសម្នាក់ទៀត កំពុងហូបស្រាបៀរពួកខ្លួនក៏បានចូលហូបជាមួយទៅ ដល់ម៉ោង ០៩ និង ០០នាទី ពួកខ្លួនផឹកអស់ស្រាបៀរចំនួន ០១កេសក៏បាននាំគ្នាដើរទៅមើលល្ខោននៅក្នុងវត្តស្វាយរមៀត ដល់ម៉ោង ១១យប់ ពួកខ្លួនបានដើរមកផ្ទះកន្លែងហូបស្រាបៀរវិញ ពេលមកដល់ឈ្មោះ អ៊ី ជិះម៉ូតូម៉ាក IVINER X ពណ៌បៃតង ឌុបមនុស្សប្រុសម្នាក់មិនស្គាល់ឈ្មោះ ដែលហូបស្រាបៀរជាម្ចាស់ផ្ទះដំបូងចេញទៅមុខវត្តស្វាយរមៀត មនុស្សម្នាក់នោះឮថានៅឃុំព្រះប្រសប់ បានបន្តិចក៏បានឃើញឈ្មោះ អ៊ី និងមនុស្សម្នាក់នោះរត់មកប្រាប់ពួកខ្លួនថា គេដេញកាប់ និងកាប់ម៉ូតូ ភ្លាមនោះខ្លួនរួមជាមួយអ៊ី និងមនុស្សនៅឃុំព្រះប្រសប់ យកកាំបិតខ្វែវមួយដែរ ចំណែកមនុស្សជាម្ចាស់ផ្ទះ និងមនុស្សដែលឈ្មោះ អ៊ី ឌុបមកដំបូងមិនទៅទេ ពេលទៅដល់មុខវត្តនោះឃើញមនុស្សជាច្រើននាក់ កំពុងនៅប្រោងប្រាងរកចូលវាយពួកខ្លួន ឯពួកខ្លួនក៏ចូលទៅដេញកាប់ពួកនោះ ពួកក្រុមមនុស្សនោះបាននាំគ្នារត់គេចអស់ និងបានបន្សល់ទុកម៉ូតូម៉ាកស្កុបពីចំនួន ០១ដែលដួលចោលនៅទីនោះ ពួកខ្លួនក៏បាននាំគ្នាកាប់ម៉ូតូឱ្យខូចខាតបាក់បែក ឯក្រុមមនុស្សនោះបានលើកគ្នាមកកាន់តែច្រើនទៀត ពួកខ្លួនក៏បាននាំគ្នារត់ត្រឡប់មកវិញ ទុកម៉ូតូម៉ាក IVINER.X ចោលនៅទីនោះ ខ្លួនជាមួយឈ្មោះ អ៊ី និងមនុស្សប្រុសដែលជាម្ចាស់ផ្ទះបានសំងំដេកនៅទីនោះ ឯមនុស្សប្រុសមិនស្គាល់ចំនួន ០២នាក់ទៀតបាត់មិនដឹងទៅណាទេ។ ដល់ព្រឹកឡើងម៉ោង០៨ និង ០០នាទី ថ្ងៃទី២៦ ខែមិថុនា ឆ្នាំ២០២៣ ពួកខ្លួនឮគេប្រាប់ថា ម៉ូតូម៉ាក IVINER.X ត្រូវសមត្ថកិច្ចយកទៅដាក់នៅប៉ុស្តិ៍ស្វាយរមៀត ខ្លួន និងឈ្មោះ អ៊ី បានចូលខ្លួនទៅសុំយកម៉ូតូ ក៏ត្រូវបានសមត្ថកិច្ចឃាត់ខ្លួនពួកខ្លួនទាំងពីរនាក់តែម្តង។

២- ជនជាប់ចោទឈ្មោះ [redacted] ម៉េងអ៊ី បានឆ្លើយថា: នៅថ្ងៃទី២៥ ខែមិថុនា ឆ្នាំ២០២៣ វេលាម៉ោង ៦ល្ងាច ខ្លួនបានទៅផឹកស្រាបៀរនៅផ្ទះរបស់ឈ្មោះ ណាក់ និងថ្លៃប្រុសវា ពេលផឹកអស់ស្រាបៀរចំនួន ០២កំប៉ុងខ្លួនបានទៅឌុបមនុស្សប្រុសម្នាក់ហៅថាប្រូៗ នៅភូមិព្រះប្រសប់ ឃុំព្រះប្រសប់ មកផឹកស្រាបៀរជាមួយដែរ លុះផឹកអស់ចំនួន ០២កំប៉ុង មនុស្សប្រុសដែលខ្លួនហៅថា ប្រូៗនោះបានខ្ចីម៉ូតូខ្លួនម៉ាក IVINER.X ពណ៌ខ្មៅលាយបៃតង ពាក់ស្លាកលេខ ភ្នំពេញ 1KC-6216 ជិះទៅទិសខាងត្បូងបាត់ បន្ទាប់មកខ្លួនខ្ចីម៉ូតូអ្នកផឹកជាមួយគ្នាជិះទៅយកឈ្មោះ [redacted] រាជសី មកផឹកនៅផ្ទះរបស់ឈ្មោះ ណាក់ ដែរ។ លុះដល់ម៉ោង ៧យប់ ខ្លួនបានឆាតឱ្យមនុស្សប្រុសដែលខ្លួនហៅថា ប្រូៗ ឱ្យយកម៉ូតូឱ្យខ្លួនវិញ ពេលមនុស្សប្រុសនោះមកដល់ក៏បានផឹកស្រាបៀរបន្ត ពេលផឹកអស់មួយកេស ខ្លួន និងឈ្មោះ [redacted] រាជសី ឈ្មោះ ណាក់ និងមនុស្សប្រុសដែលខ្លួនហៅប្រូៗ នាំគ្នាទៅមើលល្ខោននៅក្នុងវត្តស្វាយរមៀត ស្រាប់តែឈ្មោះ បាវ ភេទប្រុស អាយុ ២៣ឆ្នាំ នៅឃុំព្រះប្រសប់ ជិះម៉ូតូមកដល់ទុកម៉ូតូហើយដើរជាមួយពួកខ្លួន លុះដល់ម៉ោង ១០យប់ ពួកខ្លួនបានដើរមកផ្ទះរបស់ឈ្មោះ ណាក់ វិញ ដល់ម៉ោង ១១យប់ មនុស្សប្រុសដែលខ្លួនហៅថា ប្រូៗ បានឱ្យខ្លួនឌុបទៅក្នុងវត្តស្វាយរមៀត ទៅដល់ខ្លួនបានឃើញមនុស្សប្រុសមួយក្រុម ខ្លួនមិនស្គាល់ឈ្មោះនោះទេ មានគ្នាប្រហែល ១០នាក់ កំពុងអង្គុយផឹកស៊ីមុខវិហារ មនុស្សប្រុសនោះក៏ចាប់ហ្គារម៉ូតូរោទិ៍ម៉ូតូឮសំឡេងខ្លាំងៗដាក់មនុស្សប្រុសមួយក្រុមនោះ រួចនាំគ្នាជិះចេញមកឈប់នៅមុខក្លោងទ្វារវត្តជាប់ផ្លូវថ្នល់ ភ្លាមនោះមនុស្សប្រុសមួយក្រុមដែលកំពុងផឹកស៊ីនោះបាននាំគ្នាជិះម៉ូតូដេញវាយពួកខ្លួនត្រូវជាច្រើនដៃ ទើបខ្លួនផ្តួលម៉ូតូរត់ហើយមនុស្សប្រុសម្នាក់ទៀតរត់មកវាយខ្លួន ខ្លួនក៏បានរត់ចូលផ្ទះគេឃើញដំបងឬស្សីក៏កាន់វាយមនុស្សប្រុសនោះចំនួន ០៣ដំបងចំក្បាល រួចខ្លួនក៏បានរត់ទៅប្រាប់គ្នីគ្នាខ្លួននៅផ្ទះឈ្មោះ ណាក់ ទើបឈ្មោះ បាវ កាន់កាំបិតខ្វែវ ឈ្មោះ [redacted] រាជសី កាន់ខ្វែវគ្មានដង និងប្រុសខ្លួនហៅថា ប្រូៗ កាន់ដាវ ឯខ្លួនកាន់ដាវដែរ ចូលទៅរកវាយពួកគេវិញ តែមនុស្សមួយក្រុមនោះរត់គេច



Scanned with CamScanner

និងមានមនុស្សប្រុសម្នាក់ដួលម៉ូតូស្កុបពី ពណ៌ខ្មៅ ឃើញដូច្នេះពួកខ្លួនក៏បាននាំគ្នាកាប់ម៉ូតូនោះ បន្ទាប់មកសមត្ថកិច្ចមកដល់ ពួកខ្លួននាំគ្នារត់គេចខ្លួន។ ដល់ថ្ងៃទី២៦ ខែមិថុនា ឆ្នាំ២០២៣ ខ្លួន និងឈ្មោះ ស្វ រាជសី នាំគ្នាទៅប៉ុស្តិ៍ស្វាយរមៀត ក៏ត្រូវសមត្ថកិច្ចឃាត់ខ្លួនសួរនាំតែម្តង។

៣- ជនជាប់ចោទឈ្មោះ [redacted] ចាន់ណា បានឆ្លើយថា: ខ្លួនមិនបានប្រព្រឹត្តដូចការចោទប្រកាន់របស់តុលាការទេ ។ នៅថ្ងៃទី២៥ ខែមិថុនា ឆ្នាំ២០២៣ ខ្លួនបានទៅផឹកស្រានៅផ្ទះរបស់ឈ្មោះ [redacted] ម៉េងអ៊ី រួចម៉ោងប្រហែល ៩យប់ ខ្លួនបានជិះម៉ូតូទៅមើលល្ខោននៅវត្តស្វាយរមៀតជាមួយឈ្មោះ [redacted] ម៉េងអ៊ី និងឈ្មោះ [redacted] រាជសី ប៉ុន្តែខ្លួនមិនបានចូលរួមធ្វើសកម្មភាពកាប់ម៉ូតូគេទេ ។

៤- អំណានចម្លើយដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] មុន្នី បានបញ្ជាក់ថា: កន្លងមកខ្លួនធ្លាប់មានទំនាស់ជាមួយក្រុមបក្ខពួករបស់ឈ្មោះ បាវ ជិះម៉ូតូមកគប់ខ្លួននៅក្នុងពេងកាហ្វេក្បែរផ្ទះខ្លួន រួចពួកវាជិះម៉ូតូរត់គេចខ្លួនបាត់អស់ទៅ។ នៅថ្ងៃទី២៥ ខែមិថុនា ឆ្នាំ២០២៣ ម៉ោង ៩យប់ ខ្លួនបានជិះម៉ូតូទៅមើលល្ខោននៅវត្តស្វាយរមៀតជាមួយឈ្មោះ សេង ពេលទៅដល់ខ្លួនអង្គុយផឹកស្រាបៀរនៅចំហៀងវិហារ មានគ្នាចំនួន ០៣នាក់ មានឈ្មោះ ចាស់,ឈ្មោះ [redacted] សៀន និងខ្លួន បាន ២០នាទី ឃើញឈ្មោះ [redacted] ភ៉ាឈី មកដល់ ខ្លួនបានហៅឈ្មោះ [redacted] ភ៉ាឈី មកផឹកជាមួយដែរ ហូតដល់ម៉ោង ១០ និង ៣០នាទី ខ្លួនឃើញមនុស្សប្រុសចំនួន ០២នាក់មិនស្គាល់ឈ្មោះ ជិះម៉ូតូ ០១គ្រឿងម៉ាកអ៊ិចសិនទ័រ ពណ៌ត្រួយចេកខ្ចីមិនចាំស្លាកលេខ មកដល់កន្លែងខ្លួន ក៏មនុស្សប្រុសម្នាក់ដកដាវដែលគេអង្គុយពីលើមកកាប់ម៉ូតូរបស់ឈ្មោះ [redacted] ភ៉ាឈី បណ្តាលឱ្យខូចខាត បន្ទាប់មកខ្លួនឡើងជិះម៉ូតូរត់ចេញមកក្រៅវត្ត មកដល់ក្លោងទ្វារវត្តខាងត្បូងចំងាយប្រហែល ១០០ម៉ែត្រ ម៉ូតូរបស់មនុស្សពីរនាក់នោះក៏បានជិះតាមពីក្រោយវាយខ្លួនមួយដំបងឬស្សីចំក្បាលបណ្តាលឱ្យបែកក្បាលចេញឈាម និងដួលម៉ូតូរបស់ឈ្មោះ [redacted] ភ៉ាឈី មនុស្សម្នាក់ជិះម៉ូតូម៉ាក អិចសិនទ័រ ជិះមកជិតខ្លួនរួចយកដាវកាប់ទៅលើឈ្មោះ [redacted] ភ៉ាឈី ចំណែកខ្លួនក៏បានរត់ចេញពីកន្លែងនោះទៅ។ ពេលនោះក្រុមជនល្មើសខ្លួនស្គាល់ម្នាក់ឈ្មោះ បាវ។

៥- អំណានចម្លើយដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] ភ៉ាឈី បានបញ្ជាក់ថា: នៅថ្ងៃទី២៥ ខែមិថុនា ឆ្នាំ២០២៣ ម៉ោង ០៩ និង ៣០នាទីយប់ ខ្លួនជិះម៉ូតូម៉ាក ស្កុបពី ពណ៌ខ្មៅ ស៊េរីឆ្នាំ២០២៣ ស្លាកលេខ ភ្នំពេញ 1KP-5516 ដឹកប្រពន្ធរបស់ខ្លួនឈ្មោះ [redacted] ចាន់រ៉េត ទៅមើលល្ខោនក្នុងវត្តស្វាយរមៀត ពេលទៅដល់ក្នុងវត្តប្រពន្ធខ្លួនអង្គុយមើលល្ខោន ខ្លួនជិះម៉ូតូទៅកន្លែងវិហារជួបឈ្មោះ [redacted] មុន្នី ឈ្មោះ ចាស់ និងឈ្មោះ [redacted] មសៀន កំពុងអង្គុយផឹកនៅកន្លែងជណ្តើរឡើងវិហារ ខ្លួនក៏បានផឹកជាមួយដោយពុំមានទំនាស់អ្វីនោះទេ។ ដល់ម៉ោង ១០ និង ៣០នាទី ពេលខ្លួនកំពុងអង្គុយផឹកនោះ ស្រាប់មានមនុស្សប្រុសពីរនាក់មិនស្គាល់ឈ្មោះ ជិះម៉ូតូម៉ាក អ៊ិចស៊ិនទ័រ ពណ៌បៃតងខ្ចី មកឈប់កន្លែងខ្លួនផឹក ពេលនោះម្នាក់អង្គុយពីក្រោយបានដកដាវពីក្រោមគូទ រួចចុះពីលើម៉ូតូយកដាវមកកាប់ម៉ូតូរបស់ខ្លួនត្រូវជាច្រើនដាវចំក្បាលម៉ូតូ ចង្កៀងម៉ូតូ និងក្បាំងម៉ូតូ ហើយមនុស្សប្រុសពីរនាក់នោះឡើងជិះម៉ូតូសំដៅមកទិសខាងលិចសំដៅក្លោងទ្វារវត្តពេលនោះខ្លួនជិះម៉ូតូឌុបឈ្មោះ [redacted] មុន្នី ដេញតាមមនុស្ស ០២នាក់នោះដើម្បីសួរនាំ ពេលមកដល់ក្លោងទ្វារវត្ត ម៉ូតូអ៊ិចស៊ិនទ័រក៏ដួល ហើយម៉ូតូខ្លួនក៏ឈប់ស្រាប់តែបក្ខពួកមនុស្សពីរនាក់នោះជាច្រើនបានស្ទុះចូលមកព្រួតកាប់ម៉ូតូខ្លួនថែមទៀត ហើយមនុស្សម្នាក់ដែលបើកម៉ូតូអ៊ិចស៊ិនទ័របានស្ទុះក្រោកហើយយកដាវពីគ្នាវា ស្ទុះមកកាប់សំដៅខ្លួន ឃើញដូច្នេះខ្លួនបានផ្តួលម៉ូតូ ហើយរត់ចេញ ហើយម្នាក់នោះបានកាប់ម៉ូតូរបស់ខ្លួនថែមទៀត ហើយបក្ខពួកវាបានយកដំបងឬស្សី វាយត្រូវក្បាលរបស់ឈ្មោះ [redacted] មុន្នី មួយដំបងបណ្តាលឱ្យបែកចេញឈាម ពេលនោះក៏មានសមត្ថកិច្ចទៅដល់ពួកវាក៏បានរត់គេចខ្លួនបាត់អស់ទៅ បន្សល់ទុកម៉ូតូចំនួន ០១គ្រឿងម៉ាក អ៊ិចស៊ីនទ័រ នៅកន្លែងកើតហេតុ ហើយសមត្ថកិច្ចបានយកម៉ូតូនោះទៅរក្សាទុកនៅប៉ុស្តិ៍ស្វាយរមៀត។ ដល់ថ្ងៃទី២៦ ខែមិថុនា



Scanned with CamScanner

ឆ្នាំ២០២៣ វេលាម៉ោង ០៨ និង ០០នាទីព្រឹក មានមនុស្សម្នាក់បានចូលមកប៉ុស្តិ៍ស្វាយរមៀត មកសុំម៉ូតូម៉ាក អ៊ិចស៊ិនទ័រ ពេលនោះខ្លួនក៏ចំណាំមុខម្នាក់នោះជាអ្នកបើកម៉ូតូ និងកាប់ម៉ូតូរបស់ខ្លួនកាលពីយប់មិញ ទើបខ្លួនសុំឱ្យសមត្ថកិច្ចឃាត់ខ្លួនមនុស្សនោះ។

៦- តំណាងអយ្យការបានធ្វើសេចក្តីសន្និដ្ឋានថា៖ តាមចម្លើយរបស់ជនជាប់ចោទ និងរបាយការណ៍សរុប ព្រមទាំងភស្តុតាងនានាបង្ហាញឱ្យឃើញថា ជនជាប់ចោទឈ្មោះ លី ម៉េងអ៊ី, ឈ្មោះ [redacted] រាជសី និងឈ្មោះ [redacted] ចាន់ណា ពិតជាបានធ្វើសកម្មភាពយកដំបងវាយជនរងគ្រោះបណ្តាលឲ្យរងរបួស និងបានកាប់ម៉ូតូជនរងគ្រោះបណ្តាលឲ្យខូចខាត ប្រាកដមែន ដែលច្បាប់បានកំណត់អំពើនេះជាបទៈ ហិង្សាដោយចេតនាមានស្ថានទម្ងន់ទោស និងធ្វើឱ្យខូចខាតដោយចេតនាមានស្ថានទម្ងន់ទោស ប្រព្រឹត្តនៅភូមិព្រៃកតាបែន ឃុំស្វាយរមៀត ស្រុកខ្សាច់កណ្តាល ខេត្តកណ្តាល កាលពីថ្ងៃទី២៥ ខែមិថុនា ឆ្នាំ២០២៣ តាមបញ្ញត្តិមាត្រា ២១៨ និងមាត្រា ៤១១ នៃក្រមព្រហ្មទណ្ឌ ។

៦-លោក [redacted] ជាមេធាវីការពារសិទ្ធិឲ្យជនជាប់ចោទឈ្មោះ [redacted] ម៉េងអ៊ី បានធ្វើសេចក្តីសន្និដ្ឋានថាៈ តាមការសួរដេញដោលឃើញថា កូនក្តីរបស់ខ្លួនមិនមានចេតនាវាយទៅលើជនរងគ្រោះទេ ប៉ុន្តែដោយសារជនរងគ្រោះបានវាយលើកូនក្តីខ្លួនមុន ព្រោះតែការពារខ្លួនទើប កូនក្តីខ្លួនចាប់ទាញដំបងពីជនរងគ្រោះបានកាន់ជាប់ទុកការពារខ្លួន ហើយក៏បានវាយបកទៅលើជនរងគ្រោះវិញ នេះបញ្ជាក់ឲ្យឃើញថា ជាការការពារខ្លួនស្របច្បាប់ ចំពោះការកាប់ម៉ូតូជនរងគ្រោះ កូនក្តីរបស់ខ្លួនក៏បានបញ្ជាក់ថា មិនបានកាប់ទេ ដូច្នេះ ខ្លួនស្នើសុំឲ្យតុលាការពិចារណាបន្ធូរបន្ថយទោសឲ្យកូនក្តីខ្លួនដោយក្តីអនុគ្រោះផង ។

-ក្រោយពីបានស្តាប់ចម្លើយជនជាប់ចោទ
-ក្រោយស្តាប់អំណានចម្លើយដើមបណ្តឹងរដ្ឋប្បវេណី
-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងអយ្យការ
-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់មេធាវីការពារសិទ្ធិឲ្យជនជាប់ចោទ
- ក្រោយស្តាប់សំដីចុងក្រោយរបស់ជនជាប់ចោទ
-ក្រោយពីបានថយទៅពិនិត្យ និងពិចារណាត្រឹមត្រូវតាមច្បាប់ហើយ

**យល់ឃើញថា**

**ក/ អំពីពិរុទ្ធភាព**

១-តាមដីកាដំណោះស្រាយលេខ ១១៧២ ដកជស ចុះថ្ងៃទី១២ ខែកញ្ញា ឆ្នាំ២០២៣ ឃើញថាជនជាប់ចោទឈ្មោះ [redacted] រាជសី,ឈ្មោះ [redacted] ម៉េងអ៊ី (អត្តសញ្ញាណខាងលើ) និងជនជាប់ចោទឈ្មោះ [redacted] ចាន់ណា ត្រូវបានចៅក្រមស៊ើបសួរសាលាដំបូងខេត្តកណ្តាលបញ្ជូនមកជំនុំជម្រះពីបទៈ ហិង្សាដោយចេតនាមានស្ថានទម្ងន់ទោស និងធ្វើឱ្យខូចខាតដោយចេតនាមានស្ថានទម្ងន់ទោស ប្រព្រឹត្តនៅភូមិព្រៃកតាបែន ឃុំស្វាយរមៀត ស្រុកខ្សាច់កណ្តាល ខេត្តកណ្តាល កាលពីថ្ងៃទី២៥ ខែមិថុនា ឆ្នាំ២០២៣ តាមបញ្ញត្តិមាត្រា ២១៨ និងមាត្រា ៤១១ នៃក្រមព្រហ្មទណ្ឌ។

២- តាមចម្លើយជនជាប់ចោទឈ្មោះ [redacted] រាជសី បង្ហាញឱ្យឃើញថា៖ ខ្លួនពិតជាបានចូលរួមទៅដេញកាប់គ្នីគ្នារបស់ជនរងគ្រោះ ហើយពួកក្រុមរបស់ជនរងគ្រោះនោះបាននាំគ្នារត់គេចអស់ និងបានបន្សល់ទុកម៉ូតូម៉ាកស្កុបពីចំនួន ០១ដែលដួលចោលនៅទីនោះ ពួកខ្លួនក៏បាននាំគ្នាកាប់ម៉ូតូឱ្យខូចខាតបាក់បែក ប្រាកដមែន។

៣- តាមចម្លើយរបស់ជនជាប់ចោទឈ្មោះ [redacted] ម៉េងអ៊ី បង្ហាញឱ្យឃើញថាៈ ខ្លួនពិតជាបានចាប់ហ្គារម៉ូតូពេទីម៉ូតូឮសំឡេងខ្លាំងៗដាក់មនុស្សប្រុសមួយក្រុម រួចនាំគ្នាជិះចេញមកឈប់នៅមុខក្លោងទ្វារវត្តជាប់ផ្លូវថ្នល់



Scanned with CamScanner

ភ្លាមនោះ មនុស្សប្រុសមួយក្រុមដែលខ្លួនបានពេទ៍ម៉ូតូដាក់នោះបាននាំគ្នាជិះម៉ូតូដេញវាយពួកខ្លួនត្រូវជាច្រើនដៃ ទើបខ្លួនផ្ដួលម៉ូតូរត់ហើយមនុស្សប្រុសម្នាក់ទៀតរត់មកវាយខ្លួន ខ្លួនក៏បានរត់ចូលផ្ទះគេឃើញដំបងឬស្សីក៏កាន់វាយមនុស្សប្រុសនោះចំនួន ០៣ដំបងចំក្បាល រួចខ្លួនក៏បានរត់ទៅប្រាប់គ្នីគ្នាខ្លួននៅផ្ទះឈ្មោះ ណាក់ ទើបឈ្មោះ បាវ កាន់កាំបិតខ្មែរ ឈ្មោះ [redacted] រាជសី កាន់ខ្មែរត្បានដង និងមនុស្សប្រុសខ្លួនហៅថា ប្រុ១ កាន់ដាវ ឯខ្លួនកាន់ដាវដែរ ចូលទៅរកវាយពួកគេវិញ តែមនុស្សមួយក្រុមនោះរត់គេច និងមានមនុស្សប្រុសម្នាក់ដួលម៉ូតូស្កុបពី ពណ៌ខ្មៅ ឃើញដូច្នេះពួកខ្លួនក៏បាននាំគ្នាកាប់ម៉ូតូនោះ បណ្ដាលឱ្យមានការខូចខាត និងបាក់បែកប្រាកដមែន។

៤- តាមចម្លើយជនជាប់ចោទឈ្មោះ [redacted] ចាន់ណា បានឆ្លើយថា: ខ្លួនមិនបានប្រព្រឹត្តដូចការចោទប្រកាន់របស់តុលាការទេ ។ នៅថ្ងៃទី២៥ ខែមិថុនា ឆ្នាំ២០២៣ ខ្លួនបានទៅផឹកស្រានៅផ្ទះរបស់ឈ្មោះ [redacted] ម៉េងអ៊ី រួចម៉ោងប្រហែល ៩យប់ ខ្លួនបានជិះម៉ូតូទៅមើលល្ខោននៅវត្តស្វាយរមៀតជាមួយឈ្មោះ [redacted] ម៉េងអ៊ី និងឈ្មោះ [redacted] រាជសី ប៉ុន្តែខ្លួនមិនបានចូលរួមធ្វើសកម្មភាពកាប់ម៉ូតូគេទេ ។

៥- តាមអំណានចម្លើយដើមបណ្ដឹងរដ្ឋប្បវេណីឈ្មោះ [redacted] មុន្នី បង្ហាញឱ្យឃើញថា:ខ្លួនបានឃើញមនុស្សប្រុសចំនួន ០២នាក់មិនស្គាល់ឈ្មោះ ជិះម៉ូតូ ០១គ្រឿងម៉ាកអ៊ិចសិនទ័រ ពណ៌ត្រួយចេកខ្ចីមិនចាំស្លាកលេខ មកដល់កន្លែងខ្លួន ក៏មានមនុស្សប្រុសម្នាក់ដែលអង្គុយពីក្រោយ ដកដាវដែលគេអង្គុយពីលើមកកាប់ម៉ូតូរបស់ឈ្មោះ [redacted] វ៉ាឈី បណ្ដាលឱ្យខូចខាត បន្ទាប់មកខ្លួនឡើងជិះម៉ូតូរត់ចេញមកក្រៅវត្ត មកដល់ក្លោងទ្វារវត្តខាងត្បូងចំងាយប្រហែល ១០០ម៉ែត្រ ម៉ូតូរបស់មនុស្សពីរនាក់នោះក៏បានជិះតាមពីក្រោយវាយខ្លួនមួយដំបងឬស្សីចំក្បាលបណ្ដាលឱ្យបែកក្បាលចេញឈាម និងដួលម៉ូតូរបស់ឈ្មោះ [redacted] វ៉ាឈី មនុស្សម្នាក់ជិះម៉ូតូម៉ាក អ៊ិចសិនទ័រ ជិះមកជិតខ្លួនរួចយកដាវកាប់ទៅលើឈ្មោះ [redacted] វ៉ាឈី រួចខ្លួនក៏បានរត់ចេញពីកន្លែងនោះទៅ។

៦- តាមអំណានចម្លើយរបស់ដើមបណ្ដឹងរដ្ឋប្បវេណីឈ្មោះ [redacted] វ៉ាឈី បង្ហាញឱ្យឃើញថា:នៅវេលាម៉ោង ១០ និង ៣០នាទី ពេលខ្លួនកំពុងអង្គុយផឹក ស្រាប់តែមានមនុស្សប្រុសពីរនាក់មិនស្គាល់ឈ្មោះ ជិះម៉ូតូម៉ាកអ៊ិចស៊ិនទ័រ ពណ៌បៃតងខ្ចី មកឈប់កន្លែងខ្លួនផឹក ពេលនោះម្នាក់អង្គុយពីក្រោយបានដកដាវពីក្រោមគូថ រួចចុះពីលើម៉ូតូយកដាវមកកាប់ម៉ូតូរបស់ខ្លួនត្រូវជាច្រើនដាវចំក្បាលម៉ូតូ ចង្កៀងម៉ូតូ និងក្បាំងម៉ូតូ ហើយមនុស្សប្រុសពីរនាក់នោះឡើងជិះម៉ូតូសំដៅមកទិសខាងលិចសំដៅក្លោងទ្វារវត្ត ពេលនោះខ្លួនជិះម៉ូតូឌុបឈ្មោះ [redacted] មុន្នី ដេញតាមមនុស្ស ០២នាក់នោះដើម្បីសួរនាំ ពេលមកដល់ក្លោងទ្វារវត្ត ម៉ូតូអ៊ិចស៊ិនទ័រក៏ដួល ហើយម៉ូតូខ្លួនក៏ឈប់ស្រាប់តែបក្ខពួកមនុស្សពីរនាក់នោះជាច្រើនបានស្ទុះចូលមកព្រួតកាប់ម៉ូតូខ្លួនថែមទៀត ហើយមនុស្សម្នាក់ដែលបើកម៉ូតូអ៊ិចស៊ិនទ័របានស្ទុះក្រោកហើយយកដាវពីគ្នាវា ស្ទុះមកកាប់សំដៅខ្លួន ឃើញដូច្នេះខ្លួនបានផ្ដួលម៉ូតូ ហើយរត់ចេញ ហើយម្នាក់នោះបានកាប់ម៉ូតូរបស់ខ្លួនថែមទៀត ហើយបក្ខពួកវាបានយកដំបងឬស្សីវាយត្រូវក្បាលរបស់ឈ្មោះ [redacted] មុន្នី មួយដំបងបណ្ដាលឱ្យបែកចេញឈាម ពេលនោះក៏មានសមត្ថកិច្ចទៅដល់ពួកវាក៏បានរត់គេចខ្លួនបាត់អស់ទៅ បន្សល់ទុកម៉ូតូចំនួន ០១គ្រឿងម៉ាក អ៊ិចស៊ីនទ័រ នៅកន្លែងកើតហេតុហើយសមត្ថកិច្ចបានយកម៉ូតូនោះទៅរក្សាទុកនៅប៉ុស្តិ៍ស្វាយរមៀតតែម្ដង។

៧- តាមរបាយការណ៍សរុបលេខ ២៩៤ របក ចុះថ្ងៃទី២៧ ខែមិថុនា ឆ្នាំ២០២៣ របស់អធិការដ្ឋាននគរបាលស្រុកខ្សាច់កណ្ដាល បានធ្វើសេចក្ដីសន្និដ្ឋានថា:ឈ្មោះ [redacted] ម៉េងអ៊ី ភេទប្រុស អាយុ ២០ឆ្នាំ ឈ្មោះ [redacted] រាជសី ភេទប្រុស អាយុ ២១ឆ្នាំ និងឈ្មោះ [redacted] ចាន់ណា ភេទប្រុស អាយុ ២៣ឆ្នាំ ពិតជាបានប្រព្រឹត្តអំពើហិង្សាដោយចេតនា និងធ្វើឱ្យខូចខាតដោយចេតនា ទៅលើឈ្មោះ [redacted] មុន្នី និងឈ្មោះ [redacted] វ៉ាឈី កាលពីថ្ងៃទី២៥ ខែមិថុនា ឆ្នាំ២០២៣ វេលាម៉ោង ២២ និង ៣០នាទី នៅភូមិព្រែកបែន ឃុំស្វាយរមៀត ស្រុកខ្សាច់កណ្ដាល ខេត្តកណ្ដាល ពិតប្រាកដមែន។



Scanned with CamScanner

៨- តាមសេចក្ដីសន្និដ្ឋានរបស់តំណាងអយ្យការបង្ហាញឱ្យឃើញថា ៖ តាមចម្លើយរបស់ជនជាប់ចោទ តាមអំណានចម្លើយរបស់ដើមបណ្ដឹងរដ្ឋប្បវេណី និងរបាយការណ៍សរុប ព្រមទាំងភស្តុតាងនានា អាចបញ្ជាក់បានថា ជនជាប់ចោទឈ្មោះ [redacted] ម៉េងអ៊ី, ឈ្មោះ [redacted]រាជសី និងជនជាប់ចោទឈ្មោះ [redacted] ចាន់ណា ពិតជាបានធ្វើសកម្មភាពវាយទៅលើជនរងគ្រោះ និងបានយកដាវកាប់ទៅលើម៉ូតូជនរងគ្រោះត្រូវជាច្រើនដាវ ចំក្បាលម៉ូតូ ចង្កៀងម៉ូតូ និងក្បាំងម៉ូតូ បណ្ដាលឱ្យខូចខាតប្រាកដមែន។

៩- តាមរបាយការណ៍របស់នគរបាលយុត្តិធម៌ ចម្លើយជនជាប់ចោទ អំណានចម្លើយរបស់ដើមបណ្ដឹងរដ្ឋប្បវេណី សេចក្ដីសន្និដ្ឋានតំណាងអយ្យការ ព្រមទាំងភស្តុតាងនានា មានភាពស៊ីសង្វាក់គ្នាបង្ហាញឱ្យឃើញថា នៅថ្ងៃកើតហេតុជនជាប់ចោទឈ្មោះ [redacted] ម៉េងអ៊ី, ឈ្មោះ [redacted]រាជសី និងជនជាប់ចោទឈ្មោះ [redacted] ចាន់ណា ពិតធ្វើសកម្មភាពវាយទៅលើជនរងគ្រោះបណ្ដាលឱ្យបែកក្បាលហូរឈាម និងយកដាវកាប់ទៅលើម៉ូតូរបស់ជនរងគ្រោះជាច្រើនដាវត្រូវចំក្បាលម៉ូតូ ចង្កៀងម៉ូតូ និងក្បាំងម៉ូតូ ប្រាកដមែន ដែលអំពើដែលបានប្រព្រឹត្តនៅភូមិព្រៃកតាបែន ឃុំដំស្វាយរមៀត ស្រុកខ្សាច់កណ្ដាល ខេត្តកណ្ដាល កាលពីថ្ងៃទី២៥ ខែមិថុនា ឆ្នាំ២០២៣ ត្រូវបានច្បាប់បញ្ញត្តិថាជាបទៈ ហិង្សាដោយចេតនាមានស្ថានទម្ងន់ទោស និងធ្វើឱ្យខូចខាតដោយចេតនាមានស្ថានទម្ងន់ទោស តាមបញ្ញត្តិមាត្រា ២១៨ និងមាត្រា ៤១១ នៃក្រមព្រហ្មទណ្ឌ។

១០- ជនជាប់ចោទឈ្មោះ [redacted] ម៉េងអ៊ី,ឈ្មោះ [redacted] រាជសី និងជនជាប់ចោទឈ្មោះ [redacted] ចាន់ណា ជានីតិជនមានសមត្ថភាពគ្រប់គ្រាន់ក្នុងការទទួលខុសត្រូវចំពោះអំពើ និងព្យសនកម្ម ដែលកើតចេញពីអំពើរបស់ខ្លួន ។

១១- អំពើរបស់ជនជាប់ចោទឈ្មោះ [redacted] ម៉េងអ៊ី,ឈ្មោះ [redacted] រាជសី និងជនជាប់ចោទឈ្មោះ [redacted] ចាន់ណា ដែលបានប្រព្រឹត្តមានផលប៉ះពាល់ដល់សណ្ដាប់ធ្នាប់សាធារណៈ និងរបៀបរៀបរយសង្គម។

១២- មានធាតុផ្សំនៃបទល្មើស និងភស្តុតាងគ្រប់គ្រាន់ដើម្បីបញ្ជាក់អំពីពិរុទ្ធភាពលើជនជាប់ចោទឈ្មោះ [redacted] ម៉េងអ៊ី, ឈ្មោះ [redacted] រាជសី (អត្តសញ្ញាណខាងលើ) និងជនជាប់ចោទឈ្មោះ [redacted] ចាន់ណា (អត្តសញ្ញាណខាងលើ) ពីបទៈ ហិង្សាដោយចេតនាមានស្ថានទម្ងន់ទោស និងធ្វើឱ្យខូចខាតដោយចេតនាមានស្ថានទម្ងន់ទោស ប្រព្រឹត្តនៅភូមិព្រៃកតាបែន ឃុំស្វាយរមៀត ស្រុកខ្សាច់កណ្ដាល ខេត្តកណ្ដាល កាលពីថ្ងៃទី២៥ ខែមិថុនា ឆ្នាំ២០២៣ តាមបញ្ញត្តិមាត្រា ២១៨ និងមាត្រា ៤១១ នៃក្រមព្រហ្មទណ្ឌ។

១៣- ដើម្បីជៀសវាងការលំបាកក្នុងការចាប់ខ្លួន គប្បីតុលាការសម្រេចបញ្ឈប់ដីកាចាប់ខ្លួនលេខ ៥៤១ ដបចខ/២៣ ចុះថ្ងៃទី២៣ ខែសីហា ឆ្នាំ២០២៣ របស់ចៅក្រមស៊ើបសួរសាលាដំបូងខេត្តកណ្ដាល ដោយចេញដោយចេញដីកាបង្គាប់ឱ្យចាប់ខ្លួនលើជនជាប់ចោទឈ្មោះ អាន ចាន់ណា (អត្តសញ្ញាណខាងលើ) ដោយចៅក្រមជំនុំជម្រះជំនួសវិញ។

**ខ/ អំពីវត្ថុចាប់យក**

- កាំបិតខ្មែរចំនួន ០១ ដើម និងដាវដែកចំនួន ០១ ដើម។

**គ/អំពីសំណង**

- ក្នុងការទាមទារសំណងរដ្ឋប្បវេណី ឃើញថាដើមបណ្ដឹងរដ្ឋប្បវេណីឈ្មោះ [redacted]រ៉ាឈី និងដើមបណ្ដឹងរដ្ឋប្បវេណីឈ្មោះ [redacted] មុន្នី មិនបានចូលមកតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីទេ ចំណុចនេះគប្បីតុលាការមិនលើកយកមកពិចារណា ។

**<u>ហេតុដូច្នេះសម្រេច</u>**

១- ផ្ដន្ទាទោសលើជនជាប់ចោទ៖



Scanned with CamScanner

១.១-ឈ្មោះ [redacted] ម៉េងអ៊ី (អត្តសញ្ញាណខាងលើ) ដាក់ពន្ធនាគារកំណត់រយៈពេល ០៣ (បី) ឆ្នាំ តែទោសនេះអនុវត្តក្នុងពន្ធនាគាររយៈពេល ១៨ (ដប់ប្រាំបី) ខែ ទោសនៅសល់ព្យួរធម្មតា ។

១.២-ឈ្មោះ [redacted] រាជសី (អត្តសញ្ញាណខាងលើ) ដាក់ពន្ធនាគារកំណត់រយៈពេល ០៣ (បី) ឆ្នាំ តែទោសនេះអនុវត្តក្នុងពន្ធនាគាររយៈពេល ១៨ (ដប់ប្រាំបី) ខែ ទោសនៅសល់ព្យួរធម្មតា។

១.៣-ឈ្មោះ [redacted] ចាន់ណា(អត្តសញ្ញាណខាងលើ) ដាក់ពន្ធនាគារកំណត់រយៈពេល ០៣ (បី) ឆ្នាំ តែទោសនេះអនុវត្តក្នុងពន្ធនាគាររយៈពេល ១៨ (ដប់ប្រាំបី) ខែ ទោសនៅសល់ព្យួរធម្មតា។

ពីបទៈ**ហិង្សាដោយចេតនាមានស្ថានទម្ងន់ទោស និងធ្វើឱ្យខូចខាតដោយចេតនាមានស្ថានទម្ងន់ទោស** ប្រព្រឹត្តនៅភូមិព្រែកតាបែន ឃុំស្វាយរមៀត ស្រុកខ្សាច់កណ្តាល ខេត្តកណ្តាល កាលពីថ្ងៃទី២៥ ខែមិថុនា ឆ្នាំ ២០២៣ តាមបញ្ញត្តិមាត្រា ២១៨ និងមាត្រា ៤១១ នៃក្រមព្រហ្មទណ្ឌ។

២- រឹបអូសវត្ថុចាប់យកមានដូចជាកាំបិតខ្មែរ ចំនួន ០១ និងដាវដែកចំនួន ០១ ទុកជាទ្រព្យសម្បត្តិរដ្ឋ ។

សាលក្រមជំនុំជម្រះនៅថ្ងៃទី០៥ ខែតុលា ឆ្នាំ២០២៣ និងប្រកាសជាសាធារណៈនៅថ្ងៃទី២៦ ខែធ្នូ ឆ្នាំ ២០២៣ ចំពោះមុខជនជាប់ចោទឈ្មោះ [redacted] ម៉េងអ៊ី, ចំពោះមុខជនជាប់ចោទឈ្មោះ [redacted] រាជសី និងចំពោះមុខជនជាប់ចោទឈ្មោះ [redacted] ចាន់ណា ប៉ុន្តែកំបាំងមុខដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] មុន្នី និងដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ[redacted]រ៉ាឈី ។

ទុកសិទ្ធិប្តឹងទាស់ និងប្តឹងឧទ្ធរណ៍តាមកំណត់ច្បាប់ ។

| **ក្រឡាបញ្ជីសវនាការ** | **តំណាងអយ្យការ** | **ចៅក្រមជំនុំជម្រះ** |
|---|---|---|
| ហត្ថលេខា និងត្រា | ហត្ថលេខា និងត្រា | ហត្ថលេខា និងត្រា |

[redacted]

---

បានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម
ថ្ងៃអង្គារ ១៤កើត ខែមិគសិរ ឆ្នាំថោះ បញ្ចស័ក ព.ស២៥៦៧
កណ្តាល, ថ្ងៃទី២៦ ខែធ្នូ ឆ្នាំ២០២៣
**ក្រឡាបញ្ជី**

[redacted]

បានឃើញ
ថ្ងៃអង្គារ ១៤កើត ខែមិគសិរ ឆ្នាំថោះ បញ្ចស័ក ព.ស២៥៦៧
កណ្តាល, ថ្ងៃទី២៦ ខែធ្នូ ឆ្នាំ២០២៣
**ចៅក្រម**

[redacted]



Scanned with CamScanner